ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរដ្ឋប្បវេណី

-លេខ ១៥០ "ណ"

-ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០

-សំណុំរឿងរដ្ឋប្បវេណីលេខ២៥២៧

ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ វេលាម៉ោង០២ និង៣០នាទីរសៀល លើសំណុំរឿងរដ្ឋប្បវេណីលេខ២៥២៧ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ដោយមានសមាសភាព ៖

## ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ជាចៅក្រម និងជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជី

កញ្ញា [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ [redacted] សុខខេង ភេទស្រី អាយុ ៣៦ឆ្នាំ កើតថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៨២ ជនជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតនៅ[redacted] មានអាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះ [redacted] ប្ដីឈ្មោះ [redacted] ឃន "វ" មានកូន ០២នាក់ ឪពុកឈ្មោះ[redacted] សាវ៉ាត "ស" ម្ដាយឈ្មោះ [redacted] គិតអេង "វ"។

.អ្នកតំណាងដោយអាណត្តិ "ដើមចោទ" ៖ លោកមេធាវី [redacted] មានការិយាល័យក្រុមមេធាវី [redacted]

-ចុងចម្លើយឈ្មោះ [redacted] ឃន ភេទប្រុស អាយុ ៤៧ឆ្នាំ កើតថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៧១ ជនជាតិខ្មែរ មុខរបរមន្ត្រីរាជការនៅមន្ទីរសាធារណៈការរាជធានីភ្នំពេញ ទីកន្លែងកំណើតនៅ[redacted] មានអាសយដ្ឋានបច្ចុប្បន្នស្នាក់នៅ[redacted] ប្រពន្ធឈ្មោះ[redacted] សុខខេង "វ" មានកូន ០២នាក់ ឪពុកឈ្មោះ [redacted]កុន "ស" ម្ដាយឈ្មោះ[redacted] ង៉ិម "ស"។

អ្នកតំណាងដោយអាណត្តិ "ចុងចម្លើយ" ៖ លោកមេធាវី [redacted]

## I. អង្គហេតុ និងចំណុចវិវាទ

១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

ក-ប្ដឹងសុំលែងលះពីប្ដីឈ្មោះ[redacted] ឃន

ខ-សុំសិទ្ធិអំណាចមេបាលើកូនពីរនាក់ កូនទី១-ឈ្មោះ [redacted] កញ្ញានា ភេទស្រី កើតថ្ងៃទី[redacted]និង កូនទី២-ឈ្មោះ[redacted] កញ្ញូន: ភេទប្រុស កើតថ្ងៃទី[redacted]។

គ-សុំទាមទារអាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព

ឃ-សុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា៸

Scanned with CamScanner

២.ការពន្យល់គ្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩ ដើមចោទឈ្មោះ [redacted] សុខខេង និងចុងចម្លើយឈ្មោះ [redacted] ឃន បានរៀបអាពិហ៍ពិពាហ៍ជាមួយគ្នាតាមទំនៀមទំលាប់ប្រពៃណីខ្មែរ និងបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ លេខ១២.០៤.០៣.០០ លេខចុះបញ្ជី៣៤៤ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០១។ ក្នុងចំណងអាពាហ៍ពិពាហ៍នេះដើមចោទ និងចុងចម្លើយមានកូនពីរនាក់ កូនទី១-ឈ្មោះ [redacted] កញ្ញានា ភេទស្រី កើតថ្ងៃទី [redacted] និងកូនទី២-ឈ្មោះ [redacted] កញ្ញុន: ភេទប្រុស កើតថ្ងៃទី [redacted]។ ក្រោយអាពាហ៍ពិពាហ៍គូភាគីមានទ្រព្យសម្បត្តិរួមផ្ទះមួយល្វែងទទឹង ៤ម៉ែត្រ គុណ ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្ទះលេខ៨០៥ ផ្លូវលេខ៣៦៩ ភូមិអូរអណ្តូង សង្កាត់ព្រែកបា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ម៉ូតូចំនួន ៣គ្រឿង (១-ម៉ាកហុងដាឌ្រីម សេរីឆ្នាំ២០១៧ ពាក់ស្លាកលេខភ្នំពេញ1NG-2985 ២-ម៉ាកហ្សូមមឺអិច (Zoomer X) ពាក់ស្លាកលេខភ្នំពេញ 1DD-5336 ៣-ម៉ាកវីវ៉ា(VIVA) ពាក់ស្លាកលេខភ្នំពេញ1O-9937) និងខ្សែកមាសទម្ងន់ ១ដំឡឹង ៣ជី និងទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទមានដីទំហំ៥,៥ម៉ែត្រ គុណ បណ្តោយ១០២ម៉ែត្រ។ ដើមចោទឈ្មោះ [redacted] សុខខេង បានដាក់ពាក្យបណ្តឹងសុំលែងលះពីប្តីឈ្មោះ [redacted] ឃន ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា មានការទាស់ពាក្យសំដីគ្នាជាញឹកញាប់ ដែលជាហេតុធ្វើឱ្យដើមចោទ និងចុងចម្លើយអស់មនោសញ្ចេតនាមិនអាចបន្តរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធបន្តទៀតបានឡើយ។

៣.អង្គហេតុដែលអះអាងដោយដើមចោទឈ្មោះ [redacted] សុខខេង មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិថា: ខ្លួនសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ឃន ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា ទាស់សំដីគ្នាជាញឹកញាប់ ដែលជាហេតុធ្វើឱ្យពួកខ្លួនទាំងពីរនាក់អស់មនោសញ្ចេតនាមិនអាចបន្តរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធបន្តទៀតបានឡើយ។ ក្នុងការរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធពួកខ្លួនមានកូនពីរនាក់ កូនទី១-ឈ្មោះ [redacted] កញ្ញានា ភេទស្រី កើតថ្ងៃទី៣០ ខែ [redacted] និងកូនទី២-ឈ្មោះ [redacted] កញ្ញុន: ភេទប្រុស កើតថ្ងៃទី [redacted] ខ្លួនសុំសិទ្ធិជាអ្នកមានអំណាចមេបាលើកូន ទោះបីជាកូនស្រីច្បងគាត់មាននីតិភាពទៅហើយក្តី ប៉ុន្តែគាត់នៅកំពុងសិក្សានៅឡើយដែលត្រូវការការមើលថែទាំពីសំណាក់ខ្លួនជាម្តាយនៅឡើយ ចំពោះអាហារកាតព្វកិច្ចចិញ្ចឹមកូនទាំងពីរនាក់នេះខ្លួនជាអ្នកទទួលបន្ទុកដោយខ្លួនឯងទាំងស្រុងមិនទាមទារពីចុងចម្លើយនោះទេ។ ចំពោះទ្រព្យសម្បត្តិរួមទាំងអស់ពួកខ្លួនបានឯកភាពគ្នាប្រគល់មកឱ្យខ្លួនជាម្ចាស់កម្មសិទ្ធិទាំងអស់ ហើយរូបខ្លួនសុខចិត្តប្រគល់ប្រាក់ឱ្យទៅចុងចម្លើយចំនួន១២,០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក។ ចំណែកបំណុលរួមពួកខ្លួនពុំមាននោះឡើយ។

៤.អង្គហេតុដែលអះអាងដោយចុងចម្លើយឈ្មោះ [redacted] ឃន មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិថា ខ្លួនឯកភាពចំពោះការសុំលែងលះរបស់ដើមចោទ ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា ដែលជាហេតុធ្វើឱ្យពួកខ្លួនទាំងពីរអស់មនោសញ្ចេតនាមិនអាចបន្តរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធតទៅទៀតបានឡើយ។ ក្នុងចំណងអាពាហ៍ពិពាហ៍នេះពួកខ្លួនមានកូនពីរនាក់ កូនទី១-ឈ្មោះ [redacted] កញ្ញានា ភេទស្រី កើតថ្ងៃទី [redacted] និងកូនទី២-ឈ្មោះ [redacted] កញ្ញុន: ភេទប្រុស កើតថ្ងៃទី [redacted] ខ្លួនឯកភាពប្រគល់ឱ្យដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់។ ចំណែកទ្រព្យសម្បត្តិរួមពួកខ្លួនបានព្រមព្រៀងគ្នាប្រគល់ឱ្យភាគីដើមចោទជាម្ចាស់កម្មសិទ្ធិទាំងអស់ និងសុខចិត្តទទួលយកប្រាក់ចំនួន ១២,០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក ពីដើមចោទ រីឯបំណុលរួមពួកខ្លួនពុំមាននោះទេ។

៥.ចំណុចគ្មានវិវាទ

-គូភាគីឯកភាពគ្នាលែងលះ

-គូភាគីឯកភាពគ្នាលើសិទ្ធិអំណាចមេបាលើកូន✓



Scanned with CamScanner

-គូភាគីឯកភាពគ្នាលើទ្រព្យសម្បត្តិរួម

៦.ចំណុចវិវាទ-គ្មាន

## II.ភាពពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.១.ឯកសារ ១$_{៩}$ ៖ សំបុត្រអាពាហ៍ពិពាហ៍លេខ១២.០៤.០៣.០០ លេខចុះបញ្ជី៣៣៤ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០១ ចំនួន ០១(មួយ)ច្បាប់ (ថតចម្លង)។

១.២.ឯកសារ ១$_{៨}$ ៖ អត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែរលេខ០១១០៤៨៣៤០ ចុះថ្ងៃទី១៧ ខែកញ្ញ ឆ្នាំ២០១៥ របស់ឈ្មោះ ពេញ សុខខេង ចំនួន ០១(មួយ)ច្បាប់ (ថតចម្លង)។

១.៣.ឯកសារ ១$_{៧}$ ៖ លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ៤២៤ប/ជ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ចំនួន ០១(មួយ)ច្បាប់ (ថតចម្លង)។

១.៤.ឯកសារ ១$_{៦}$ ៖ សៀវភៅគ្រួសារ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ ចំនួន ០១(មួយ)ច្បាប់ (ថតចម្លង)។

១.៥.ឯកសារ ១$_{៥}$ ៖ សៀវភៅស្នាក់នៅលេខ០៧៧៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ របស់អធិការនគរបាលខណ្ឌច្បារអំពៅ ចំនួន ០១(មួយ)ច្បាប់ (ថតចម្លង)។

១.៦.ឯកសារ ១$_{៤}$ ៖ លិខិតឆ្លងដែនលេខN00287002 ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] សុខខេង ចំនួន ០១(មួយ)ច្បាប់ (ថតចម្លង)។

១.៧.ឯកសារ ១$_{៣}$ ៖ រូបថតរៀបអាពាហ៍ពិពាហ៍របស់ឈ្មោះ [redacted] សុខខេង និងឈ្មោះ [redacted] យេន ចំនួន ០៤(បួន)សន្លឹក។

១.៨.ឯកសារ ៦$_{៤}$ ៖ លិខិតបញ្ជាក់ទំហំដី ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ ចេញដោយមេភូមិអូរអណ្តូង ចំនួន ០១(មួយយ)ច្បាប់ (ច្បាប់ដើម)។

១.៩.ឯកសារ ៦$_{៣}$ ៖ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ៣៣១ នៃសៀវភៅបញ្ជាក់កំណើតលេខ០៤/២០១៩ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] កញ្ញានា ចំនួន ០១(មួយ)ច្បាប់ (ថតចម្លង)។

១.១០.ឯកសារ ៦$_{២}$ ៖ សេចក្តីចម្លងសំបុត្រកំណើតលេខ១៤៧ នៃសៀវភៅកំណើតលេខ០៤/២០០៥ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] កញ្ញនៈ ចំនួន ០១(មួយ)ច្បាប់ (ថតចម្លង)។

១.១១.ឯកសារ ៦$_{១}$ ៖ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ៥០៧៩ នៃសៀវភៅបញ្ជាក់កំណើតលេខ៩៥/២០០៥ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុខខេង ចំនួន ០១(មួយ)ច្បាប់ (ថតចម្លង)។

១.១២.ឯកសារ ២០$_{៤}$ ៖ សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់មេធាវី [redacted] ចំនួន ០១(មួយ)ច្បាប់ (ច្បាប់ដើម)។

**២.ភស្តុតាងជាឯកសាររបស់ចុងចម្លើយ-គ្មាន**

**៣.ការសាកសួរសាក្សី-គ្មាន**

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា ៖

១-ដើមចោទ និងចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ប្រាកដមែន ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ១២.០៤.០៣.០០ លេខចុះបញ្ជី៣៣៤ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០១ ផ្អែកតាមមូលហេតុដែលភាគីបានអះអាង និងទទួលស្គាល់ថាក្នុងការរស់នៅមិនចុះសម្រុងនឹងគ្នា ទាស់សំដីគ្នាជាញឹកញាប់ និងបានរស់នៅបែកគ្នា ដែលជា



Scanned with CamScanner

ហេតុនាំឲ្យរស់មនោសញ្ចេតនាជាប្ដីប្រពន្ធតទៅទៀត ហើយបានឯកភាពក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្តប្រាកដមែន ហេតុនេះតុលាការគប្បីសម្រេចតាមការព្រមព្រៀង តាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី។

២-ក្នុងចំណងអាពាហ៍ពិពាហ៍ដើមចោទ និងចុងចម្លើយមានកូនពីរនាក់ កូនទី១-ឈ្មោះ [redacted] កញ្ញានា ភេទស្រី កើតថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០១ និងកូនទី២-ឈ្មោះ [redacted] កញ្ញេនះ ភេទប្រុស កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥ គូភាគីបានព្រមព្រៀងគ្នា ដោយកំណត់ឲ្យដើមចោទឈ្មោះ [redacted] សុខខេង ជាអ្នកមានអំណាចមេបាលើកូនប្រុសឈ្មោះ [redacted] កញ្ញេនះ ចំណែកកូនស្រីឈ្មោះ [redacted] កញ្ញានា មាននីតិភាពរួចហើយ ប៉ុន្តែស្ថិតនៅក្រោមការគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាពីដើមចោទជាម្ដាយនៅឡើយព្រោះនៅកំពុងសិក្សានៅឡើយ ហេតុនេះតុលាការគប្បីសម្រេចតាមការព្រមព្រៀង តាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី។

៣-ថ្វីត្បិតតែភាគីដើមចោទមានអំណាចមេបា ពុំបានទាមទារឲ្យចុងចម្លើយផ្ដល់អាហារកាតព្វកិច្ចចិញ្ចឹមកូន អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៤៧ ដែលបានចែង "អំពីមាតាបិតាមានកាតព្វកិច្ចបីបាច់ថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ" និងមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ក៏បានចែងផងដែរអំពីសិទ្ធិ និងករណីកិច្ចរបស់ឪពុកម្ដាយ(ពុំមានអំណាចមេបា) ដែលមិនរស់នៅជាមួយកូនក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន។

ហេតុនេះ គប្បីឲ្យភាគីចុងចម្លើយមានសិទ្ធិដូចច្បាប់ចែងក្នុងមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី តែភាគីចុងចម្លើយត្រូវទទួលស្គាល់អំពីផលប្រយោជន៍របស់កូនជាអាទិភាព។

៤-អំពីទ្រព្យសម្បត្តិរួម ៖

ក-ផ្អែកតាមការអះអាង និងទទួលស្គាល់ដោយដើមចោទ និងភាគីចុងចម្លើយមានដូចជា:

-ផ្ទះមួយល្វែងទទឹង ៤ម៉ែត្រ គុណ ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្ទះលេខ៨០៥ ផ្លូវលេខ៣៦៩ ភូមិត្នោតជ្រុំ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

-ម៉ូតូម៉ាកហុងដាឌ្រីម សេរីឆ្នាំ២០១៧ ពាក់ស្លាកលេខភ្នំពេញ1NG-2985 ចំនួន ១(មួយ)គ្រឿង។

-ម៉ូតូម៉ាកហ្សូមមីអិច(Zoomer X) ពាក់ស្លាកលេខភ្នំពេញ 1DD-5336 ចំនួន ១(មួយ)គ្រឿង។

ខ-ការបែងចែកទ្រព្យរួម៖

-ភាគីចុងចម្លើយឈ្មោះ [redacted] ឃន សុខចិត្តទទួលយកប្រាក់ចំនួន១២,០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក ជាថ្នូរតបស្នងនៃការបែងចែកទ្រព្យរួមចំណុច(ក) ហើយសុខចិត្តប្រគល់ទ្រព្យរួមទាំងអស់ទៅឲ្យភាគីដើមចោទឈ្មោះ [redacted] សុខខេង គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ។

-ភាគីដើមចោទឈ្មោះ [redacted] សុខខេង សុខចិត្តទទួលយកទ្រព្យរួមទាំងអស់មកកាន់កាប់តែម្នាក់ឯង ហើយប្រគល់ប្រាក់ចំនួន១២,០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក ទៅឲ្យចុងចម្លើយតាមការព្រមព្រៀង។

គប្បីតុលាការយកជាមូលដ្ឋានសម្រេចតាមឆន្ទៈព្រមព្រៀងរបស់គូភាគី។

៥-ផ្អែកតាមមាត្រា៦៤ ចំណុចទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការគប្បីពិចារណាលើប្រាក់ប្រដាប់ក្ដី។

## សេចក្ដីសម្រេចបញ្ចប់

១-លែងលះដើមចោទឈ្មោះ [redacted] សុខខេង និងចុងចម្លើយឈ្មោះ [redacted] ឃន។

២-កំណត់យកឈ្មោះ [redacted] សុខខេង ត្រូវជាម្ដាយមានអំណាចមេបា គ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា អប់រំ រៀនសូត្រលើកូនឈ្មោះ [redacted] កញ្ញេនះ ភេទប្រុស កើតថ្ងៃទី [redacted] រហូតដល់កូនធំពេញនីតិភាព។/

បើកសិទ្ធិឱ្យភាគីចុងចម្លើយ (ឪពុក) ចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងជួយឧបត្ថមតាមលទ្ធភាពបានគ្រប់ពេលវេលាតែមិនត្រូវឱ្យប៉ះពាល់ដល់ការសិក្សារបស់កូន ហើយភាគីដើមចោទមិនត្រូវធ្វើសកម្មភាពណាមួយរារាំងឡើយ។

៣-ឱ្យដើមចោទឈ្មោះ [redacted] សុខខេង ប្រគល់ប្រាក់ចំនួន ១២,០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក ទៅចុងចម្លើយឈ្មោះ លេវ ឃេន។

៤-ប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់ឱ្យទៅដើមចោទឈ្មោះ [redacted] សុខខេង ជាម្ចាស់កម្មសិទ្ធិមានដូចខាងក្រោម ៖

-ផ្ទះមួយល្វែងទទឹង ៤ម៉ែត្រ គុណ ១៦ម៉ែត្រ មានទីតាំងស្ថិតនៅផ្ទះលេខ៨០៥ ផ្លូវលេខ៣៦៩ ភូមិអូរអណ្តូង សង្កាត់ព្រែកបា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

-ម៉ូតូម៉ាកហុងដាឌ្រីម សេរីឆ្នាំ២០១៧ ពាក់ស្លាកលេខភ្នំពេញ1NG-2985 ចំនួន ១(មួយ)គ្រឿង។

-ម៉ូតូម៉ាកហ្សូមមឺអិច(Zoomer X) ពាក់ស្លាកលេខភ្នំពេញ 1DD-5336 ចំនួន ១(មួយ)គ្រឿង។

៥ -ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះត្រូវបានប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។៚

ចៅក្រម

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រម

[redacted]



Scanned with CamScanner